ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៥៧១ សសរ.កសក

# សេចក្តីសម្រេច

## ស្តីពីការបង្កើតក្រុមការងារតាមដាន និងដោះស្រាយបញ្ហាប្រឈមលើផលិតកម្មកសិកម្ម និងការរកទីផ្សារកសិផល

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្ម ឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញសេចក្តីសម្រេចលេខ២៧២ សសរ.កសក ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦ ស្តីពីរបៀបរបបការងារនិងបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញសេចក្តីសម្រេចលេខ២៩៧ សសរ.កសក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១:** ត្រូវបានបង្កើតក្រុមការងារតាមដាន និងដោះស្រាយបញ្ហាប្រឈមលើផលិតកម្មកសិកម្ម និងការរកទីផ្សារកសិផល ដែលមានសមាសភាពដូចខាងក្រោម៖

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣)៧២៦ ១២៨ /៧២៦ ១២៩ ទូរសារលេខ: (៨៥៥)២៣-២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

| | | |
|---|---|---|
| ១-ឯកឧត្តម **ទី សុគន្ធ** | រដ្ឋលេខាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២-ឯកឧត្តម **អ៊ឹង ហុកលីម** | អនុរដ្ឋលេខាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៣-ឯកឧត្តម **ហ៊ីត ប៊ុនណារី** | អនុរដ្ឋលេខាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤-លោកជំទាវ **ម៉ុម ថានី** | អនុរដ្ឋលេខាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៥-ឯកឧត្តម **គង់ ចាន់** | អនុរដ្ឋលេខាធិការនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៦-លោក **ម៉ាក់ សឿន** | អគ្គនាយករងទទួលបន្ទុករួមនៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិកអចិន្ត្រៃយ៍ |
| ៧-លោក **ស្រី វុឌ្ឍី** | ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ | សមាជិក |
| ៨-លោក **គង់ តាដ** | ប្រធាននាយកដ្ឋានកសិឧស្សាហកម្ម | សមាជិក |
| ៩-លោក **កែ មុន្នីវុធ** | ប្រធាននាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ | សមាជិក |
| ១០-លោក **ឱន ឆាយ** | ប្រធាននាយកដ្ឋានដំណាំស្រូវ | សមាជិក |
| ១១-លោក **ជា សាំងជូណា** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម | សមាជិក |
| ១២-លោក **ហូ ពុទ្ធា** | ប្រធាននាយកដ្ឋានសាកវប្បកម្មនិងដំណាំរួមផ្សំ | សមាជិក |
| ១៣-លោក **ខាន់ សំបាន** | ប្រធាននាយកដ្ឋានដំណាំឧស្សាហកម្ម | សមាជិក |
| ១៤-លោក **ចាន់ សារុទ្ធ** | ប្រធាននាយកដ្ឋានវិស្វកម្មកសិកម្ម | សមាជិក |
| ១៥-លោក **ម៉ុច ចន្ថា** | អនុប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម | សមាជិក |
| ១៦-លោក **ម៉ិច ធុច** | អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល | សមាជិក |
| ១៧-លោកប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត | | សមាជិក |
| ១៨-លោក **ឡោ វ៉ាន់ណុល** | ប្រធានការិយាល័យវិវាទនៃនាយកដ្ឋាននីតិកម្មកសិកម្ម | លេខាធិការ |
| ១៩-លោក **មៀច យ៉ាឌី** | ប្រធានការិ.ទីផ្សារនៃនាយកដ្ឋានផែនការនិងស្ថិតិ | លេខាធិការ |

**ប្រការ២:** ក្រុមការងារនេះមានភារកិច្ចដូចខាងក្រោម៖

- តាមដានការគ្រប់គ្រង និងត្រួតពិនិត្យគុណភាព និងសុវត្ថិភាពកសិផល
- ជំរុញកំណើនផលិតភាពកសិកម្មតាមរយៈពិពិធកម្មកសិកម្ម និងការអនុវត្តកសិកម្មល្អប្រកបដោយភាពវៃឆ្លាត
- តាមដានការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពធាតុចូលកសិកម្ម
- រិះរកមធ្យោបាយដើម្បីជំរុញឲ្យកសិករចេះធ្វើការវិភាគតាមរយៈការកាត់បន្ថយថ្លៃដើម ការបង្កើនចំណូលដល់កសិករ និងតម្លៃបន្ថែមលើកសិផល
- តាមដាន និងអន្តរាគមន៍ដោះស្រាយឲ្យបានទាន់ពេលវេលានូវបញ្ហាប្រឈមលើផលិតកម្មកសិកម្ម និងទីផ្សារកសិផល
- រាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងករណីចាំបាច់។

**ប្រការ៣:** -សមាជិកនៃក្រុមការងារនេះត្រូវអនុវត្តភារកិច្ចតាមការចាត់តាំង និងចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន

-ករណីប្រធានក្រុមការងារជាប់បេសកកម្ម ត្រូវប្រគល់សិទ្ធិជូនអនុរដ្ឋលេខាធិការជាអនុប្រធានទទួលបន្ទុកដឹកនាំជំនួស។

**ប្រការ៤:** សេចក្ដីសម្រេចទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៥:** អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល ÷**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៥
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ